ការិយាល័យ អគ្គនាយក
440 North Broad Street
Philadelphia, PA 1913

**William R. Hite, Jr., Ed.D.**
អគ្គនាយក

ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២០

ជូនចំពោះ ក្រុមគ្រួសារ របស់ក្រសួងអប់រំ ជាទីគោរព៖

ក្រសួងអប់រំនៃរដ្ឋ ផិនស៊ីលវេនីញ៉ា (PDE) បានប្រកាសនៅថ្ងៃនេះថា សាលារៀនទាំងអស់នៅរដ្ឋ ផិនស៊ីលវេនីញ៉ា រួមទាំងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀនឹងត្រូវបន្តបិទទ្វារយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០២០ ដោយសារលទ្ធផលនៃការឆ្លើយតបទៅនឹងមេរោគ ខូវីដ-១៩។

នៅពេលដែលផលប៉ះពាល់នៃមេរោគ ខូវីដ-១៩(មេរោគខូរ៉ូណា) កាន់តែមានសភាពខ្លាំងក្លានៅក្នុងតំបន់ហ្វីឡាដែលហ្វៀ ក្រសួងអប់រំរបស់យើងផ្តោតការយកចិត្តទុកដាក់ទៅលើ ការរក និង សមភាព នៃវិធីថ្មីៗ ដែលយើងអាចជួយដល់តម្រូវការរបស់សិស្សានុសិស្ស ក្រុមគ្រួសារ និង បុគ្គលិក របស់យើង នៅពេលដែលសាលាបន្តបិទទ្វារ។ សេចក្តីណែនាំដែលយើងកំពុងទទួលពី ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនីញ៉ា និង ក្រសួងអប់រំនៃសហរដ្ឋអាមេរិក គឺកំពុងតែមានការប្រែប្រួល ហើយការឆ្លើយតបរបស់យើងនឹងមានការប្រែប្រួលនៅពេលមាន ព័ត៌មាន និង សេចក្តីណែនាំ បន្ថែមទៀត។ លិខិតនេះផ្តល់ព័ត៌មានថ្មីៗអំពីផែនការរបស់យើង ដល់សិស្សានុ សិស្សទាំងអស់។

យើងកំពុងបង្កើតការសិក្សាពីផ្ទះ សម្រាប់សិស្សានុសិស្សទាំងអស់ រួមជាមួយផែនការផ្តល់សម្ភារៈដល់សិស្សានុសិស្ស ដើម្បីធានាឱ្យបាននូវសមភាព។ យើងក៏កំពុងរៀបចំ ការបណ្តុះបណ្តាល និង ប្រភពជំនួយ តាមអុីនធំរណិត ដើម្បីឱ្យលោកគ្រូអ្នកគ្រូកាន់តែច្រើនអាចរក្សាទំនាក់ទំនងជាមួយសិស្សានុសិស្ស ដោយប្រើ ថ្នាក់រៀនហ្គូហ្គោល (Google Classroom)។ យើងនឹងជូនព័ត៌មាន លម្អិត និងកាលបរិច្ឆេទ បន្ថែមទៀតនាពេលខាងមុខនេះ។

យើងក៏កំពុងពង្រឹងបន្ថែមទៀត នូវវិធីដែលយើងបម្រើ សិស្សានុសិស្ស និង ក្រុមគ្រួសារ របស់យើង ក្នុងអំឡុងពេលនេះ ដោយ៖

- កិច្ចប្រឹងប្រែងពង្រីកបណ្តាញខ្សែទូរសព្ទសំខាន់ៗរបស់យើងនៅថ្ងៃនេះ ដោយដាក់បញ្ចូលបណ្តាញខ្សែទូរសព្ទសំខាន់ៗចំនួន ៩ បន្ថែមទៀត ជាភាសាផ្សេងៗ ដើម្បីឱ្យក្រុមគ្រួសារជាច្រើនអាចទទួលបានចម្លើយទៅនឹងសំណួរជាទូទៅមួយចំនួន ជាភាសាកំណើតរបស់ពួកគាត់។ បណ្តាញខ្សែទូរសព្ទសំខាន់ៗទាំងនេះដំណើរការពីថ្ងៃចន្ទ ដល់ព្រឹកថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩ និង ៣០ នាទី ដល់ម៉ោង ១១ និង ៣០ នាទីព្រឹក។
    - ២១៥-៤០០-៥៣០០ - អង់គ្លេស
    - ២១៥-៤០០-៨៨៨៩ - អេស្ប៉ាញ
    - ២១៥-៤០០-៨៨៨០ - អាល់បានី
    - ២១៥-៤០០-៨៨៨១ - អារ៉ាប់
    - ២១៥-៤០០-៨៨៨២ - ចិន
    - ២១៥-៤០០-៨៨៨៣ - បារាំង
    - ២១៥-៤០០-៨៨៨៤ - ខ្មែរ
    - ២១៥-៤០០-៨៨៧៤ - ព័រទុយហ្គាល់

- ២១៥-៤០០-៨៥៨៥ - រុស្ស៊ី
- ២១៥-៤០០-៨៥៨៦ - វៀតណាម

- បង្កើតអ៊ីម៉ែល covid19info@philasd.org ថ្មីមួយ ដែលក្រុមគ្រួសារអាចផ្ញើសំណួររបស់ពួកគាត់ ដើម្បីទទួលការឆ្លើយតប។
- នៅថ្ងៃអង្គារ ទី ២៤ ខែមីនា ចាប់ផ្តើមទំព័រវិបសៃថ្មីមួយនៅ www.philasd.org ដែលមានចម្លើយទៅនឹងសំណួរដែលគេឧស្សាហ៍សួរ។
- ផ្តល់ជូននូវការណែនាំអំពីការសិក្សា ពីថ្នាក់ មត្តេយ្យ ដល់ថ្នាក់ទី ១២ (LGs) តាមអ៊ីនធំណេិតសម្រាប់សិស្សានុសិស្ស ដែលចាប់ផ្តើមពីថ្ងៃពុធ ទី ២៥ ខែមីនា និងជាក្រដាស នៅគ្រប់ទីតាំងផ្តល់ម្ហូបអាហារទាំង ៤៩ របស់ក្រសួងអប់រំ ដែលចាប់ផ្តើមពីថ្ងៃព្រហស្បតិ៍ ទី ២៦ ខែមីនា។
  *(កន្លែងផ្តល់ម្ហូបអាហាររបស់ក្រសួង ឥឡូវនេះដំណើរការតែនៅថ្ងៃច័ន្ទ និង ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩ ព្រឹក ដល់ថ្ងៃត្រង់។ ម្តងអាចយក អាហារពេលព្រឹក ៣ និង អាហារថ្ងៃត្រង់ ៣ សម្រាប់សិស្សម្នាក់ៗដែលរស់នៅក្នុងគ្រួសាររបស់លោកអ្នក)។*
- ជាការបញ្ជាក់បន្ថែមទៀត ជំនួយពីលោកគ្រូអ្នកគ្រូរបស់យើងអាចផ្តល់ដល់សិស្សរួមមានៈ ការប្រាស្រ័យទាក់ទងតាមរយៈ អ៊ីមែល ទូរសព្ទ ឬ វិធីផ្សេងៗទៀត ដើម្បីឆ្លើយសំណួរ និងជួយដល់ការសិក្សា។ បើកលទ្ធភាពឱ្យប្រើប្រាស់កម្មវិធីសិក្សាតាមអ៊ីនធំណេិត ដែលក្រសួងបានទិញ។ ណាត់ ពេលវេលា ឬ ម៉ោង តាមការិយាល័យក្នុងអ៊ីនធំណេិត សម្រាប់ សិស្សម្នាក់ៗ ឬ ជាក្រុម ដើម្បី "ជួប" ជាមួយគ្រូរបស់ពួកគេ។ និងប្រាប់ពីប្រភពជំនួយផ្សេងៗទៀតសម្រាប់ឱ្យសិស្សប្រើ ដើម្បីជួយដល់ការសិក្សា។
- ចែករំលែកជាមួយ គ្រូ និង ក្រុមគ្រួសារ នូវជំនួយនៃការណែនាំដោយខ្លួនឯង និង ជំនួយតាមអ៊ីនធំណេិត ដើម្បីឱ្យសិស្សានុសិស្ស បន្ត ចូលរួម និង រីករាយ ក្នុងការរៀនសូត្រជារៀងរាល់ថ្ងៃ។

សូមអរគុណចំពោះការបន្ត ភាពជាដៃគូ និង ការគាំទ្រ របស់លោកអ្នក នៅពេលដែលយើងកំពុងធ្វើរដំណើរក្នុងសភាពការណ៍ដែល យើងមិនអាចដឹងមុន ជាមួយគ្នា។ សូមមេត្តាថែរក្សាខ្លួន និង សូមឱ្យមានសុវត្ថិភាព!

ដោយសេចក្តីរាប់អាន



William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ